pennsylvania
DEPARTMENT OF HUMAN SERVICES

កញ្ចប់ធានារ៉ាប់រងជំនួយវេជ្ជសាស្ត្ររបស់អ្នក ត្រូវបានគេហៅថា
ភាពមានសិទ្ធិស្របច្បាប់ដែលអាចមានសម្រាប់ស្ត្រីមានផ្ទៃពោះ

# សូមស្វាគមន៍ជំនួយវេជ្ជសាស្ត្រ

## ហើយនេះជាការណែនាំដែលមានប្រយោជន៍មួយចំនួនអំពីការប្រើប្រាស់ជំនួយវេជ្ជសាស្ត្រ ៖

ត្រូវប្រាកដថា ត្រូវយកប័ណ្ណ ACCESS របស់អ្នកមកជាមួយលោកអ្នកគ្រប់ពេលវេលា ។ នៅពេលអ្នកទៅទទួលសេវាថែទាំសុខភាព សូមបង្ហាញប័ណ្ណធានារ៉ាប់រងទាំងអស់របស់អ្នក ដែលរួមមានប័ណ្ណ ACCESS របស់អ្នក ។

ប្រសិនបើលោកអ្នកត្រូវការប័ណ្ណ ACCESS ថ្មី សូមហៅទូរស័ព្ទ ៖ 1-877-395-8930. ប្រសិនបើលោកអ្នករស់នៅរដ្ឋ Philadelphia សូមហៅទូរស័ព្ទលេខ ៖ 1-215-560-7226.

មានការកំណត់លក្ខខណ្ឌចំពោះប្រភេទសេវាកម្មដែលអ្នកអាចទទួលបាន ។ សូមពិភាក្សាជាមួយអ្នកផ្តល់សេវាកម្មរបស់អ្នក ឬហៅទូរស័ព្ទលេខ 1-800-537-8862, ជម្រើស #2, #3, #2 អំពីការកំណត់លក្ខខណ្ឌទាំងនេះ ។

សម្រាប់ព័ត៌មានបន្ថែមអំពីអ្វីដែលត្រូវរាប់បញ្ចូលក្នុងសេវាកម្មទាំងនេះ សូមហៅទូរស័ព្ទ ៖ 1-800-537-8862, ជម្រើស #2, #3, #2.

## អ្នកអាចទទួលបានសេវាកម្មទាំងនេះ* ៖

- សេវាកម្មរថយន្តសង្គ្រោះ
- មន្ទីរពេទ្យវះកាត់អ្នកជំងឺដែលមិនសង្គ្រោះបន្ទាន់ (ASC)
- ការគ្រប់គ្រងសំណុំរឿង
- សេវាកម្មព្យាបាលឆ្អឹងខ្នង
- សេវាកម្មគ្លីនិក
- សេវាកម្មធ្មេញ
- សេវាកម្មគ្រឿងញៀននិងគ្រឿងស្រវឹង
- ឧបករណ៍វេជ្ជសាស្ត្រដែលប្រើបានយូរអង្វែង (រួមបញ្ចូលទាំងឧបករណ៍រណបឆ្អឹង (Orthotics) និងឧបករណ៍ដាក់ជំនួសសរីរាង្គកាត់ចោល (Prosthetics))
- សេវាកម្មនិងការផ្តត់ផ្គង់ធ្វើផែនការគ្រួសារ
- សេវាកម្មមន្ទីរពេទ្យមើលថែរក្សាអ្នកជំងឺចុងក្រោយ
- ការធ្វើតេស្តមន្ទីរពិសោធន៍
- សេវាកម្មមន្ទីរសម្ភពដោយគ្រូពេទ្យ ឆ្មបគិលានុបដ្ឋាយិកាដែលមានលិខិតបញ្ជាក់ មន្ទីរសម្រាលកូល និងការមកជួបទៅពិនិត្យនៅផ្ទះដោយគិលានុបដ្ឋាយិកា
- ការផ្គត់ផ្គង់វេជ្ជសាស្ត្រ
- សេវាសុខភាពផ្លូវចិត្ត
- សេវាកម្មអ្នកឯកទេសពិនិត្យភ្នែកនិងប្រើឡង់ទី
- សេវាកម្មគ្រូពេទ្យព្យាបាលជើងនិងកជើង
- ឱសថមានវេជ្ជបញ្ជា
- សេវាកម្មថតកាំរស្មីវិទ្យុសកម្ម (កាំរស្មី X-Rays, MRIs, CTs)
- សេវាកម្មថែទាំមុខងារតម្រងនោម
- សេវាកម្មមន្ទីរថែទាំមនុស្សចាស់
- ជំនួយមធ្យោបាយដឹកជញ្ជូន

* សេវាកម្មអ្នកជំងឺសម្រាកក្នុងមន្ទីពេទ្យដែលចេញថ្លៃធានារ៉ាប់រង ។

pennsylvania
DEPARTMENT OF HUMAN SERVICES

សូមកត់សម្គាល់ថាកញ្ចប់ធានារ៉ាប់រងនេះ បំពេញតាមតម្រូវការទាមទារនៃការចេញថ្លៃធានារ៉ាប់រងពិសេសកម្រិតអប្បបរមា ដែលមានសេចក្តីលម្អិតក្រោមច្បាប់ស្តីពីការថែទាំសុខភាពដែលអាចចំណាយបាន ។

កញ្ចប់ធានារ៉ាប់រងជំនួយវេជ្ជសាស្រ្តរបស់អ្នក ត្រូវបានគេហៅថាជា**មនុស្សពេញវ័យ** និងសម្រាប់ប្រជាពលរដ្ឋដែលមានអាយុ 21 ឆ្នាំ និងអាយុច្រើនជាងនេះ

# សូមស្វាគមន៍ជំនួយវេជ្ជសាស្រ្ត

## ហើយនេះជាការណែនាំដែលមានប្រយោជន៍មួយចំនួនអំពីការប្រើប្រាស់ជំនួយវេជ្ជសាស្រ្ត ៖

- ត្រូវប្រាកដថា ត្រូវយកប័ណ្ណ ACCESS របស់អ្នកមកជាមួយលោកអ្នកគ្រប់ពេលវេលា ។ នៅពេលអ្នកទៅទទួលសេវាថែទាំសុខភាព សូមបង្ហាញប័ណ្ណធានារ៉ាប់រងទាំងអស់របស់អ្នក ដែលរួមមានប័ណ្ណ ACCESS របស់អ្នក ។
- ប្រសិនបើលោកអ្នកត្រូវការប័ណ្ណ ACCESS ថ្មី សូមហៅទូរស័ព្ទ ៖ 1-877-395-8930. ប្រសិនបើលោកអ្នករស់នៅរដ្ឋ Philadelphia សូមហៅទូរស័ព្ទលេខ ៖ 1-215-560-7226.

## លោកអ្នកអាចទទួលបានសេវាកម្មទាំងនេះ ៖

- សេវាកម្មអ្នកហ្វឹកហាត់អនុវត្តការងារគិលានុបដ្ឋាយិកាដែលបានចុះបញ្ជីបញ្ជាក់ត្រឹមត្រូវ
- សេវាកម្មព្យាបាលឆ្អឹងខ្នង
- សេវាកម្មគ្លីនិក
- សេវាកម្មវិបត្តិ
- កែវភ្នែកប្លាស្ទិកស្តើងៗ (មានកំណត់លក្ខខណ្ឌចំពោះបុគ្គលដែលមានអាបផាកៀ (aphakia))
- សេវាកម្មថែទាំសុខភាពធ្មេញ
- គ្រឿងបរិក្ខារពេទ្យដែលប្រើបានយូរអង្វែង
- បន្ទប់សង្គ្រោះបន្ទាន់/សេវារថយន្តសង្គ្រោះ
- ដងវ៉ែនតា (មានកំណត់លក្ខខណ្ឌចំពោះបុគ្គលដែលមានអាបផាកៀ (aphakia))
- កញ្ចក់វ៉ែនតា (មានកំណត់លក្ខខណ្ឌចំពោះបុគ្គលដែលមានអាបផាកៀ (aphakia))
- សេវាកម្ម និងការផ្គត់ផ្គង់ធ្វើផែនការគ្រួសារ
- សេវាកម្មមណ្ឌលសុខភាពមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ថ្នាក់សហព័ន្ធ/សេវាកម្មគ្លីនីកសុខភាពជនបទ
- សេវាកម្មសុខភាពតាមផ្ទះ
- សេវាកម្មមន្ទីរពេទ្យមើលថែរក្សាអ្នកជំងឺចុងក្រោយ
- ICF/IID និង ICF/ORC (តម្រូវឱ្យមានកម្រិតថែទាំសុខភាពនៃស្ថាប័ន)
- សេវាកម្មព្យាបាលគ្រឿងញៀននិងគ្រឿងស្រវឹងសម្រាប់អ្នកជំងឺសម្រាកក្នុងមន្ទីរពេទ្យ
- សេវាកម្មមន្ទីរពេទ្យសម្រាប់អ្នកដេកក្នុងមន្ទីរពេទ្យ
- សេវាកម្មសុខភាពផ្លូវចិត្តសម្រាប់អ្នកដេកក្នុងមន្ទីរពេទ្យ
- សេវាកម្មមន្ទីរពិសោធន៍
- មាតុភាព - គ្រូពេទ្យ គិលានុបដ្ឋាកដែលមានលិខិតបញ្ជាក់ ឆ្មប មជ្ឈមណ្ឌលសម្រាលកូន
- ការផ្គត់ផ្គង់វេជ្ជសាស្រ្ត
- ការថែទាំមេតាដូន (Methadone)
- ការព្យាបាលសុខភាពផ្លូវចិត្តចល័ត
- មធ្យោបាយដឹកជញ្ជូនវេជ្ជសាស្រ្តមិនមែនសង្គ្រោះបន្ទាន់
- (តែទៅនិងមកពីសេវាកម្មដែលបានចេញថ្លៃធានារ៉ាប់រង)
- សេវាកម្មមន្ទីថែទាំមនុស្សចាស់
- ផលិតផលអាហារូបត្ថម្ភបន្ថែម
- សេវាកម្មអ្នកឯកទេសពិនិត្យភ្នែកនិងប្រើឡង់ទី
- សេវាកម្មព្យាបាលគ្រឿងញៀននិងគ្រឿងស្រវឹងសម្រាប់អ្នកដេកក្រៅមន្ទីរពេទ្យ
- សេវាកម្មមន្ទីរពេទ្យសម្រាប់អ្នកដេកក្រៅមន្ទីរពេទ្យ
- ការព្យាបាលផ្នែកវិកលចរិតផ្នែកខ្លះ
- សេវាកម្មគាំទ្រសមាជិក
- សេវាកម្មគ្រូពេទ្យ
- សេវាកម្មគ្រូពេទ្យព្យាបាលជើងនិងកជើង
- ឱសថមានវេជ្ជបញ្ជា
- សេវាកម្មផ្តល់សេវាថែទាំសុខភាពបឋម
- ឧបករណ៍ដាក់ជំនួសសរីរាង្គកាត់ចោល (Prosthetics) និងឧបករណ៍រណបឆ្អឹង (Orthotics) (ស្បែកជើងដាក់ជំនួសសរីរាង្គកាត់ចោល និងឧបករណ៍ជំនួយស្តាប់មិនត្រូវបានចេញថ្លៃធានារ៉ាប់រងឡើយ)
- សេវាកម្មគ្លីនិកផ្នែកវិកលចរិត
- សេវាកម្មថតកាំរស្មីវិទ្យសកម្ម (ឧទាហរណ៍ ៖ កាំរស្មីអ៊ិច x-rays, MRIs, CTs)
- សេវាកម្មថែទាំមុខងារតម្រងនោម
- សេវាកម្មគ្រប់គ្រងសំណុំរឿងតាមគោលដៅ - សុខភាពផ្លូវចិត្តតែប៉ុណ្ណោះ (មានកំណត់លក្ខខណ្ឌចំពោះបុគ្គលដែលមាន SMI តែប៉ុណ្ណោះ)
- សេវាកម្មគ្រប់គ្រងសំណុំរឿងតាមគោលដៅ - ក្រៅពីសុខភាពផ្លូវចិត្ត (មានកំណត់លក្ខខណ្ឌចំពោះបុគ្គលដែលបានកំណត់អត្តសញ្ញាណក្នុងក្រុមគោលដៅតែប៉ុណ្ណោះ)
- ការព្យាបាល (រាងកាយ ជំងឺបណ្តាលមកពីការងារ ការនិយាយ) - ការធ្វើឱ្យមាននីតិសម្បទា និងការស្តារនីតិសម្បទាឡើងវិញ (តែនៅពេលណាបានផ្តល់ជូនដោយមន្ទីរពេទ្យ អ្នកផ្តល់សេវាកម្មគ្លីនិកសម្រាប់អ្នកជំងឺដេកក្រៅមន្ទីរពេទ្យ ឬការថែទាំសុខភាពតាមផ្ទះ)
- ការបញ្ឈប់ប្រើថ្នាំជក់

ប្រសិនបើលោកអ្នកបានចុះឈ្មោះនៅក្នុងកម្មវិធី HealthChoices ឬអង្គការ Community HealthChoices Managed Care Organization (MCO) ឬកម្មវិធី LIFE សូមពិនិត្យមើលជាមួយអ្នកផ្តល់សេវាកម្ម MCO ឬ LIFE របស់អ្នក ។ អ្នកផ្តល់សេវាកម្ម MCO ឬ LIFE អាចផ្តល់សេវាកម្មច្រើនថែមទៀតជាងសេវាកម្មទាំងនោះដែលទាមទារដោយកម្មវិធីជំនួយវេជ្ជសាស្រ្ត ។

pennsylvania
DEPARTMENT OF HUMAN SERVICES

កញ្ចប់ធានារ៉ាប់រងជំនួយវេជ្ជសាស្ត្ររបស់អ្នក ត្រូវបានគេហៅថា**កុមារ** ហើយសម្រាប់ប្រជាពលរដ្ឋដែលមានអាយុក្រោម 21 ឆ្នាំ ។

# សូមស្វាគមន៍ជំនួយវេជ្ជសាស្ត្រ

## ហើយនេះជាការណែនាំដែលមានប្រយោជន៍មួយចំនួនអំពីការប្រើប្រាស់ជំនួយវេជ្ជសាស្ត្រ ៖

ត្រូវប្រាកដថា ត្រូវយកប័ណ្ណ ACCESS របស់អ្នកមកជាមួយលោកអ្នកគ្រប់ពេលវេលា ។ នៅពេលអ្នកទៅទទួលសេវាថែទាំសុខភាព សូមបង្ហាញប័ណ្ណធានារ៉ាប់រងទាំងអស់របស់អ្នក ដែលរួមមានប័ណ្ណ ACCESS របស់អ្នក ។

ប្រសិនបើលោកអ្នកត្រូវការប័ណ្ណ ACCESS ថ្មី សូមហៅទូរស័ព្ទ ៖ 1-877-395-8930. ប្រសិនបើលោកអ្នករស់នៅរដ្ឋ Philadelphia សូមហៅទូរស័ព្ទលេខ ៖ 1-215-560-7226.

សម្រាប់ព័ត៌មានបន្ថែមអំពីអ្វីដែលបានរួមបញ្ចូលនៅក្នុងសេវាថែទាំសុខភាពទាំងនេះ រួមគ្នាជាមួយនឹងដែនកំណត់ទាំងឡាយ សូមហៅទូរស័ព្ទទៅកាន់លេខ ៖ 1-800-537-8862, ជម្រើស #1, #2, #3 ។ ប្រសិនបើអ្នកត្រូវបានចុះឈ្មោះនៅក្នុងគម្រោងថែទាំសុខភាពដោយមានការគ្រប់គ្រង អ្នកត្រូវតែទូរស័ព្ទទៅគម្រោង ។

## លោកអ្នកអាចទទួលបានសេវាកម្មទាំងនេះ ៖

- សេវាកម្មរថយន្តសង្គ្រោះ/បន្ទប់សង្គ្រោះបន្ទាន់
- សេវាកម្មអ្នកហ្វឹកហាត់អនុវត្តការងារគិលានុបដ្ឋាយិកាដែលបានចុះបញ្ជីបញ្ជាក់ត្រឹមត្រូវ
- សេវាកម្មសុខភាពកុមារ (ប្រភេទថែទាំសុខភាពណាមួយដែលត្រូវការចាំបាច់ខាងវេជ្ជសាស្ត្រ ដែលរួមមានការពិនិត្យជំងឺប្រចាំឆ្នាំ)
- សេវាកម្មព្យាបាលឆ្អឹងខ្នង
- សេវាកម្មគ្លីនិក
- សេវាកម្មវិបត្តិ
- សេវាកម្មធ្មេញ
- សេវាកម្មវិភាគរោគវិនិច្ឆ័យ
- គ្រឿងបរិក្ខារពេទ្យដែលជាប់ប្រើបានយូរ
- ការត្រួតពិនិត្យជំងឺ ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលមុនពេលកំណត់ និងតាមពេលវេលាទៀងទាត់
- វ៉ែនតា
- សេវាកម្ម និងការផ្តត់ផ្គង់ធ្វើផែនការគ្រួសារ
- សេវាកម្មមណ្ឌលសុខភាពមានដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ថ្នាក់សហព័ន្ធ/សេវាកម្មមណ្ឌលសុខភាពជនបទ
- សេវាកម្មសុខភាពតាមផ្ទះ
- សេវាកម្មមន្ទីរពេទ្យមើលថែរក្សាអ្នកជំងឺចុងក្រោយ
- សេវាកម្មមន្ទីរពេទ្យសម្រាប់អ្នកដេកក្នុងមន្ទីរពេទ្យ
- សេវាកម្មថែទាំសុខភាពផ្លូវចិត្តសម្រាប់អ្នកជំងឺដេកក្នុងមន្ទីរពេទ្យនិងអ្នកជំងឺដេកក្រៅមន្ទីរពេទ្យ (ការព្យាបាលសុខភាពផ្លូវចិត្ត ឬការរំលោភបំពានប្រើសារធាតុ)
- សេវាកម្មមន្ទីរពិសោធន៍
- ការផ្គត់ផ្គង់វេជ្ជសាស្ត្រ
- មធ្យោបាយដឹកជញ្ជូនវេជ្ជសាស្ត្រមិនមែនសង្គ្រោះបន្ទាន់
- (តែទៅនិងមកពីសេវាកម្មដែលបានចេញថ្លៃធានារ៉ាប់រង)
- សេវាកម្មមន្ទីថែទាំមនុស្សចាស់
- ផលិតផលអាហារូបត្ថម្ភបន្ថែម
- សេវាកម្មព្យាបាលជំងឺពីការងារ
- សេវាកម្មអ្នកឯកទេសពិនិត្យភ្នែកនិងប្រើឡង់ទី
- សេវាកម្មមន្ទីរពេទ្យសម្រាប់អ្នកដេកក្រៅមន្ទីរពេទ្យ
- ការព្យាបាលរាងកាយ
- សេវាកម្មគ្រូពេទ្យ
- សេវាកម្មគ្រូពេទ្យព្យាបាលជើងនិងកជើង
- ឱសថមានវេជ្ជបញ្ជា
- សេវាកម្មព្យាបាលបង្ការជាមុន
- ឧបករណ៍រណបឆ្អឹង (Orthotics) និងឧបករណ៍ដាក់ជំនួសសរីរាង្គកាត់ចោល (Prosthetics)
- សេវាវាកម្មថតកាំរស្មីវិទ្យុសកម្ម (កាំរស្មី x-rays, MRIs, CTs)
- សេវាកម្មធ្វើឱ្យមាននីតិសម្បទាឡើងវិញ
- សេវាកម្មថែទាំមុខងារតម្រងនោម
- សេវាកម្មពិនិត្យជំងឺ
- សេវាកម្មនានាដែលផ្តល់ជូនដោយអ្នកផ្តល់សេវាកម្មតាមសាលារៀន
- ការផ្តល់សេវាកម្មព្យាបាលខាងការនិយាយ ការស្តាប់ និងភាសា
- សេវាកម្មគ្រប់គ្រងសំណុំរឿងតាមគោលដៅ

ប្រសិនបើលោកអ្នកបានចុះឈ្មោះក្នុងអង្គការថែទាំសុខភាព HealthChoices Managed Care Organization សូមពិនិត្យមើលជាមួយផែនការនេះ ដោយសារផែនការនេះអាចផ្តល់ជូនសេវាកម្មបន្ថែមខាងលើដែលមានតម្រូវការទាមទារដោយកម្មវិធីជំនួយវេជ្ជសាស្ត្រ ។

pennsylvania
DEPARTMENT OF HUMAN SERVICES

កញ្ចប់ធានារ៉ាប់រងជំនួយវេជ្ជសាស្ត្ររបស់អ្នក ត្រូវបានគេហៅថាកម្មវិធីសេវាកម្មផែនការគ្រួសារ(Family Planning Services program) ។

# សូមស្វាគមន៍ជំនួយវេជ្ជសាស្ត្រ

## ហើយនេះជាការណែនាំដែលមានប្រយោជន៍មួយចំនួនអំពីការប្រើប្រាស់ជំនួយវេជ្ជសាស្ត្រ ៖

ត្រូវប្រាកដថា ត្រូវយកប័ណ្ណ ACCESS របស់អ្នកមកជាមួយលោកអ្នកគ្រប់ពេលវេលា ។ ប្រសិនបើលោកអ្នកត្រូវការសេវាកម្មផែនការគ្រួសារ ឬសេវាកម្មទាក់ទងនឹងផែនការគ្រួសារ សូមបង្ហាញប័ណ្ណ ACCESS របស់អ្នក និងប័ណ្ណធានារ៉ាប់រងផ្ទាល់ខ្លួនផ្សេងទៀតដែលលោកអ្នកអាចមាន នៅពេលលោកអ្នកទទួលបានសេវាកម្មទាំងនេះ ។

ប្រសិនបើលោកអ្នកត្រូវការប័ណ្ណ ACCESS ថ្មី សូមហៅទូរស័ព្ទ ៖1-877-395-8930. ប្រសិនបើលោកអ្នករស់នៅរដ្ឋហ្វីឡាដេលហ្វី Philadelphia សូមហៅទូរស័ព្ទលេខ ៖ 1-215-560-7226.

**សូមកត់សម្គាល់ថាកញ្ចប់ធានារ៉ាប់រងនេះ មិនបំពេញតាមតម្រូវការទាមទារនៃការចេញថ្លៃធានារ៉ាប់រងពិសេសកម្រិតអប្បបរមាឡើយ ដូចដែលបានបញ្ជាក់នៅក្រោមច្បាប់ស្តីពីការថែទាំសុខភាពដែលអាចចំណាយបាន ។**

## ចំណុចខាងក្រោមនេះជាបញ្ជីសេវាកម្មខ្លះ ដែលរួមបញ្ចូលក្នុងកញ្ចប់ធានារ៉ាប់រងសេវាកម្មផែនការគ្រួសារនេះ ៖

- ការិយាល័យទៅជួបអ្នកផ្តល់សេវាកម្មថែទាំសុខភាពតាមផែនការគ្រួសាររបស់អ្នក សម្រាប់ការវាយតម្លៃ ការតាមដាន និងការបញ្ជូនអ្នកជំនាញទៅកាន់អ្នកផ្តល់សេវាកម្មថែទាំសុខភាពផ្សេងទៀតនៅពេលចាំបាច់ ។
- ការផ្តល់ប្រឹក្សាយោបល់ពីអ្នកផ្តល់សេវាកម្មថែទាំសុខភាពរបស់អ្នកដែលទាក់ទងនឹងការមានផ្ទៃពោះ ដើម្បីត្រៀមខ្លួនមានផ្ទៃពោះ ដើម្បីការពារពីការមានផ្ទៃពោះដោយចៃដន្យ នឹងដើម្បីអោយបុគ្គលនានាអាចគ្រប់គ្រងការកំណត់ពេលវេល នឹងការពន្យាពេលមានផ្ទៃពោះ ។
- ការផ្តួចផ្តើមគំនិត និងការគ្រប់គ្រងការពារមិនអោយមានកូន ដែលរួមមានការធ្វើមិនអោយមានកូនពីបុរស និងស្ត្រី ។
- ការផ្គត់ផ្គង់ និងការប្រើថ្នាំពន្យាកំណើត ។
- ការការពារជំងឺឆ្លងតាមការរួមភេទឬជំងឺកាមរោគ(STDs)ដោយប្រើវ៉ាក់សាំង និងស្រោមអនាម័យ ។
- ការព្យាបាលជំងឺឆ្លងតាមការរួមភេទឬជំងឺកាមរោគ(STDs)តាមរយៈការប្រើថ្នាំ និង/ឬតាមនីតិវិធីនានា ។
- សេវាកម្មមន្ទីរពិសោធន៍សម្រាប់ការពិនិត្យមើលជំងឺឆ្លងតាមការរួមភេទឬជំងឺកាមរោគ STDs, មេរោគហ៊ីវ HIV (មេរោគដែលបង្កជំងឺអេដស៍ AIDS), ជំងឺខ្វះឈាមក្រហម ជំងឺកោសិកាក្រហម និងការមានផ្ទៃពោះ ។
- ការពិនិត្យមើល និងការអប់រំទាក់ទងនឹងជំងឺមហារីកសុដន់ ប្រដាប់បន្តពូជ និងពងស្វាស ។
- ការពិគ្រោះយោបល់ទាក់ទងនឹងការឈប់ជក់បារី ។

ការមកជួបពិនិត្យនៅការិយាល័យផែនការគ្រួសារធម្មតាសម្រាប់ស្ត្រី អាចមាន ៖ ការពិនិត្យមើលត្រគាក; ការពិនិត្យមើលជំងឺមហារីកសុដន់និងប្រដាប់បន្តពូជ; ការពិនិត្យមើលសម្ពាធឈាមខ្ពស់ ជំងឺខ្វះឈាមក្រហម និងជំងឺទឹកនោមផ្អែម; ការធ្វើតេស្តជំងឺឆ្លងតាមការរួមភេទឬជំងឺកាមរោគ ដែលរួមមានមេរោគហ៊ីវ HIV; ការពិគ្រោះយោបល់អំពីផែនការស្ត្រីសម្រាប់ការមានផ្ទៃពោះ ហើយបើសមស្របនោះ មានការចេញវេជ្ជបញ្ជាសម្រាប់ការការពារមិនអោយមានកូន ។

ការមកជួបពិនិត្យនៅការិយាល័យផែនការគ្រួសារធម្មតាសម្រាប់បុរសអាចមាន ៖ ការធ្វើតេស្ត និងការព្យាបាលជំងឺឆ្លងតាមការរួមភេទឬជំងឺកាមរោគ STDs និងការប្រើស្រោមអនាម័យសម្រាប់ការពារ; ការធ្វើតេស្តមេរោគហ៊ីវ HIV និងការអប់រំអំពីការការពារ; ការពិនិត្យមើលពងស្វាស និងការអប់រំអំពីជំងឺមហារីកពងស្វាស; និងព័ត៌មានស្តីពីការការពារមិនអោយមានកូនប្រកបដោយសុវត្ថិភាពនិងប្រសិទ្ធភាពសម្រាប់លោកអ្នកនិងដៃគូរបស់អ្នក ។

**ប្រសិនបើលោកអ្នកមានសំណួរអំពីអ្វីដែលត្រូវចេញថ្លៃធានារ៉ាប់រងនោះ សូមពិនិត្យមើលជាមួយអ្នកផ្តល់សេវាកម្មរបស់អ្នក ។**

DUMMY BAR CODE DUMMY BAR CODE